**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**

**ប្រចាំប្រទេសជប៉ុន**

*តូក្យូ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៥*

*លេខ: 72 /១៥-តក*

*សូមគោរពជូន*
*ឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
*រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ*

***កម្មវត្ថុ*** *៖ របាយការណ៍នៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៣៤ របស់ Council Director នៅ AJC។*

***យោង*** *៖ លិខិតក្រសួងលេខ ១៤២៩ អស៊ប/កបទ.សអ ចុះថ្ងៃទី ១៨ កុម្ភៈ ឆ្នាំ ២០១៥ ។*

*ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា នៅថ្ងៃទី ៥ និង ៦ ខែមីនា ២០១៥ ខ្ញុំបាទបានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៣៤ របស់ Council Director of AJC នៅទីក្រុងតូក្យូ ដែលរបៀបវារៈនៃកិច្ចប្រជុំឆ្នាំនេះ មានចំណុចសំខាន់មួយគឺ **ការជ្រើសរើសអគ្គលេខាធិការថ្មីនៃ AJC** ជំនួសអគ្គលេខាធិការ Yoshikuni Ohnishi ដែលនឹងត្រូវចប់អាណត្តិនៅចុងខែមីនា ២០១៥ខាងមុខនេះ បន្ទាប់ពីបានបំពេញកិច្ចការពីរអាណត្តិ។ សូមគោរពរាយការណ៍ជូនពីលទ្ធផល ដូចខាងក្រោម ៖*

***១-ការជ្រើសរើស Chairperson, Vice Chairperson and Repporteur ថ្មី:***

*យោងតាម Rule 12 នៃនីតិវិធីរបស់ Council of ASEAN-Japan Centre និងការអនុវត្តតាម Alphabetical Order កិច្ចប្រជុំបានជ្រើសរើសសមាសភាព Chairperson, two Vice-chairpersons and Repporteur ថ្មី ដូចខាងក្រោម:*

- ***Mr. Rozaimee Abdullah,*** *Acting Head of Promotion of Department of Economic Cooperation of the Ministry of Foreign Affairs and Trade of Brunei Darussalam, as Chairperson*
- ***Mr. Takio Yamada,*** *Director-General of Southeast and Southwest Asian Affairs Department of the Ministry of Foreign Affairs of Japan, as Vice-Chairman and CD*
- ***H.E. Mr. Hor Monirath,*** *Ambassador of the Royal Embassy of Cambodia to Japan, as Vice-Chairperson and CD, and*
- ***Mr. Yoshikuni Ohnishi,*** *Secretary General of AJC, as Repporteur។*

***២-ការពិភាក្សាលើ Appointment of the New Secretary General of AJC:***

*ក្រសួងការបរទេសជប៉ុន បានស្នើដាក់បេក្ខភាពលោក Masataka Fujita ជាអគ្គលេខាធិការថ្មី (Secretary General) របស់ AJC ជំនួសលោក Yoshikuni Ohnishi ដែលនឹងត្រូវបញ្ចប់អាណត្តិនៅចុងខែមីនា២០១៥ខាងមុខ។ បេក្ខភាពខាងលើ **មិនទាន់ត្រូវបានអនុម័តយល់ព្រមពីសមាជិក Council Directors** នៅក្នុងកិច្ចប្រជុំលើកទី៣៤នេះនៅឡើយទេ **ដោយហេតុថា** ក្រសួងការបរទេសជប៉ុន បានស្នើសុំអង្គប្រជុំពិភាក្សាលើសំណើសុំ "**Housing Allowance & Installation Grant**" សម្រាប់លោក Fujita ដែលមិនទាន់មាន Residence នៅប្រទេសជប៉ុន ដោយលោកទើបមកពី Geneva។*

*8-6-9 AKASAKA, MINATO-KU, TOKYO 107-0052*
*Tel: (81 3)5412-8521 Fax: (81 3)5412-8526*
*E-mail : camembassyjp@gmail.com*

ដោយបារម្ភពីផលប៉ះពាល់ដល់សកម្មភាព AJC ដែលបណ្តាលពីការចំណាយខាងលើ សមាជិក Council Directors បានសម្របសម្រួល ដូចខាងក្រោម ៖

*-សម្រាប់ឆ្នាំសារពើពន្ធ ២០១៥ (សីហា ២០១៥-មីនា២០១៦):*

**"Housing Allowance និង Installation Grant"** របស់ Secretary General (SG) ថ្មី នឹងត្រូវដកយកពីប្រាក់ខែរបស់ SG ដែលមិនប្រើប្រាស់ពីខែមេសា-កក្កដា ២០១៥ មានចំនួន **¥5,004,000** សម្រាប់ចំណាយលើ **"Housing Allowance និង Installation Grant"** សម្រាប់ FY2015។

*-សម្រាប់ឆ្នាំសារពើពន្ធ ២០១៦ និង២០១៧:*

អង្គប្រជុំ បានសម្រេចបន្ថយ **"Housing Allowance និង Installation Grant"** នេះ មកនៅ **25%** សម្រាប់**ឆ្នាំ២០១៦** និង **20%** សម្រាប់**ឆ្នាំ២០១៧**។ **"Housing Allowance និង Installation Grant"** នេះ នឹងត្រូវបញ្ឈប់ផ្តល់ជូន នៅពេល SG ថ្មីនេះមានលំនៅដ្ឋានផ្ទាល់ខ្លួននៅជប៉ុន។ ពាក់ព័ន្ធនឹងករណីនេះ ភាគីជប៉ុនបានសន្យាថា នឹងខិតខំបង្កើនមូលនិធិ ដែលអាចរកបានពីប្រភពផ្សេងៗ ដើម្បីជួយលើកកំពស់សកម្មភាពការងាររបស់ AJC ដោយមិនឲ្យប៉ះពាល់ដល់វិភាគទានប្រចាំឆ្នាំរបស់សមាជិកអាស៊ាន។

ប្រធានអង្គប្រជុំលើកទី៣៤នេះ បានកំណត់ពេលត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ក្នុងការឆ្លើយតបចំពោះបេក្ខភាពរបស់លោក Masataka Fujita។

ខ្ញុំបាទសូមជម្រាបជូនឯកឧត្តមជ្រាបថា តាមការណែនាំរបស់ក្រសួង ស្ថានទូតបានផ្ញើលិខិតគាំទ្រជូនក្រសួងការបរទេសជប៉ុនរួចហើយ។ ដូច្នេះ ទោះជាមានការចំណាយលើ **"Housing Allowance និង Installation Grant"** ក៏ដោយ ក៏ជំហររបស់យើងត្រូវនៅរក្សាគាំទ្របេក្ខភាពលោក Masataka Fujita ដដែល។

ជាមួយគ្នានេះដែរ ក្នុងចន្លោះពេលអវត្តមាន SG អង្គប្រជុំបានសម្រេចចាត់តាំងលោក Dananjaya Axioma, បច្ចុប្បន្នជា Director of Tourism & Exchange of AJC ធ្វើជា Acting SG ចាប់ពីថ្ងៃទី ០១ មេសា ២០១៥ រហូតដល់ SG ថ្មី ចូលកាន់តំណែង។

**៣-របាយការណ៍ស្តីពី Achievement of FY2014 Program Activities របស់ AJC:**

នៅឆ្នាំ២០១៤នេះ AJC បានអនុវត្តសកម្មភាពការងារចំនួន ៣៤២ នៃ**កម្មវិធីការងារស្នូល ៣** គឺ: Trade & Investment, Tourism & Exchange and P.R. ដោយរួមបញ្ចូលទាំងកម្មវិធីការងារ **AMEICC** (AEM-METI Economic and Industrial Cooperation Committee) ក្រោមជំនួយឧបត្ថម្ភថវិកាបន្ថែមពីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន (METI) ដែលក្នុងនោះ កម្មវិធីការងារជម្រុញផ្នែកពាណិជ្ជកម្ម (Trade & Investment) មាន ៤២% ស្មើនឹង ១៤៥ សកម្មភាពការងារ, កម្មវិធីការងារជម្រុញផ្នែកទេសចរណ៍ និងការផ្លាស់ប្តូរ (Tourism & Exchange) មាន ២០% ស្មើនឹង ៦៨សកម្មភាពការងារ និងកម្មវិធីការងារ P.R. មាន ៣៨% ស្មើនឹង ១២៩សកម្មភាពការងារ។ បើធៀបនឹងឆ្នាំ២០១៣ សកម្មភាពការងាររបស់ AJC ឆ្នាំ២០១៤ បានកើន ៣៣% ដែលមាន ២៥៧ សកម្មភាពការងារ។ ការចំណាយលើកម្មវិធីការងារឆ្នាំ២០១៤នេះ មានចំនួនទឹកប្រាក់ **¥586,464,000** និងថវិកាបន្ថែមចំនួន **¥130,000,000** ក្រោមគម្រោងរបស់ METI។

*នៅឆ្នាំ ២០១៤ នេះ កម្ពុជាបានចូលរួមយ៉ាងសកម្មទៅក្នុងកម្មវិធីការងារស្នូលទាំង ៣ ខាងលើ ដូចខាងក្រោម:*

*-**ផ្នែកពាណិជ្ជកម្ម (Trade)**: បានចូលរួមលើកកំពស់ផលិតផលកម្ពុជាលើទីផ្សារជប៉ុន ការបង្កើតប្រព័ន្ធតភ្ជាប់ពាណិជ្ជកម្ម និងទីផ្សាររវាងជប៉ុន និងកម្ពុជាតាមរយៈការចូលរួមក្នុងកម្មវិធី Seminar on Capacity Building, Business Marching, Business Support Program, Introduction of Cambodia's Materials into Japan Fashion Business, and CLMV Support Program។*

*- **ផ្នែកវិនិយោគ (Investment)**: បានផ្សព្វផ្សាយជូនវិនិយោគិនជប៉ុនតាមរយៈ Investment Promotion Seminars, ការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយតាមគេហទំព័រ (Website) របស់ AJC, ការរៀបចំបេសកកម្មទៅកម្ពុជាដើម្បីជម្រុញវិនិយោគ, កម្មវិធីកសាងបណ្តាញទំនាក់ទំនងវិនិយោគរវាងកម្ពុជា និងជប៉ុន។*

*- **ផ្នែកទេសចរណ៍ និងការផ្លាស់ប្តូរ (Tourism & Exchange)**: បានផ្សព្វផ្សាយពីវិស័យទេចរណ៍កម្ពុជាតាមរយៈការចូលរួមរបស់កម្ពុជាក្នុង**សិក្ខាសាលាផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍កម្ពុជា, ក្នុងសិក្ខាសាលាកសាងសមត្ថភាពមន្ត្រីទេសចរណ៍ទាំងរដ្ឋាភិបាល និងវិស័យឯកជន, ក្នុងកម្មវិធីការផ្លាស់ប្តូរទស្សនកិច្ចរបស់យុវជន, និងក្នុងកម្មវិធីផ្សព្វផ្សាយពីផលិតផលទេចរណ៍ថ្មីរបស់កម្ពុជា**។*

*- **ផ្នែក P.R. (Public Relations)**: តាមរយៈកម្មវិធី P.R. នេះ កម្ពុជាទទួលបានអត្ថប្រយោជន៍លើការផ្សព្វផ្សាយទាំងផ្នែកពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ ដោយកម្មវិធីនេះបានផ្សព្វផ្សាយពិសក្តានុពលរបស់បណ្តាប្រទេសអាស៊ានលើវិស័យទាំង ៣ ខាងលើ ក្នុងនោះកម្ពុជាក៏ត្រូវបានផ្សព្វផ្សាយជូនទៅបណ្តាវិនិយោគិនធុរៈជន និងអ្នកទេសចរណ៍ជប៉ុនផងដែរ។*

*ចំពោះគម្រោងបន្ថែមក្រោមកម្មវិធី AMEICC របស់ METI បានចូលរួមចំណែកក្នុងការពង្រឹង និងពង្រីកកម្មវិធីការងាររបស់ AJC ដែលក្នុងនោះ បានលើកកំពស់ការបណ្តុះបណ្តាលស្តីពីសហគ្រិនភាព វិនិយោគ ពាណិជ្ជកម្ម និងទេសចរ តាមរយៈសិក្ខាសាលា និងទស្សនកិច្ចសិក្សា រៀបចំឡើងជូនមន្ត្រីសាធារណៈ និងឯកជនរបស់សមាជិកអាស៊ាន។*

*ខ្ញុំបាទសូមជម្រាបជូនថា នៅឆ្នាំ ២០១៤ នេះ កម្ពុជាបានអនុវត្តលើគម្រោងពីរ (២) តាមរយៈ National Activities ដូចខាងក្រោម:*

*-**ក្រសួងពាណិជ្ជកម្ម**: បានអនុវត្តគម្រោងមួយ ដោយបានរៀបចំ Workshop on Trade Support Networks and Building Connectivity of High Value Silk in Cambodia នៅថ្ងៃទី១៦ ខែធ្នូ ២០១៤ នៅភ្នំពេញ ដែលបានចំណាយថវិកាអស់ **១០.៧៧៥** ដុល្លាអាមេរិក។*

*-**ក្រសួងទេសចរណ៍**: បានអនុវត្តគម្រោងមួយ ដោយបានរៀបចំសិក្ខាសាលាស្តីពីការការពារមរតកវប្បធម៌ និងទីក្រុងឈានឆ្ពោះទៅការចុះបញ្ជីខេត្តបាត់ដំបងទៅជាទីក្រុងមរតក និងវប្បធម៌របស់ UNESCO ដែលបានរៀបចំពីថ្ងៃទី ៧-៩ ខែ មករា ឆ្នាំ ២០១៥ កន្លងមក នៅខេត្តបាត់ដំបង ដោយចំណាយថវិកាអស់ **២៨.៣២៤** ដុល្លាអាមេរិក។*

### *៤-ការអនុម័តលើការផ្ទេរ Transfer of Incremental Portion of Obligatory Contribution for FY2015 របស់សមាជិកអាស៊ាន ដើម្បីលើកកំពស់សកម្មភាពការងារសំខាន់ៗរបស់ AJC:*

*អង្គប្រជុំបានឯកភាពផ្ទេរទឹកប្រាក់ 20% (**¥ 9,959,000**) នៃថវិកាសរុប National Activities of ASEAN Member States (¥49,795,000) សម្រាប់ FY2015 ដែលជា Incremental Portion of Obligatory Contribution ចូលក្នុងគណនីរបស់ AJC ដើម្បីប្រើប្រាស់ក្នុងការពង្រឹងសកម្មភាពស្នូលរបស់ AJC នៅឆ្នាំ ២០១៥ ។*

***៥-ការអនុម័តលើការផ្ទេ Transfer of Unappropriated Balance ពី F2013 ចូលទៅក្នុងគណនី Special Fund របស់ AJC សម្រាប់ឆ្នាំ២០១៥:***

*ទន្ទឹមនឹងនោះ អង្គប្រជុំបានឯកភាពផ្ទេរទឹកប្រាក់ **¥ 42,474,868** ដែលជា Unappropriated Balance of FY2013 ចូលទៅក្នុងគណនី Special Fund របស់ AJC for FY2015 ដើម្បីប្រើប្រាស់ក្នុងការពង្រឹងប្រតិបត្តិការការងាររបស់ AJC ដែលក្នុងនោះ សម្រាប់ប្រើប្រាស់ជម្រុញសកម្មភាព Trade: 44% (¥18,808,000), Investment: 33% (¥13,955,000), Tourism & Exchange: 20% (¥8,413,000), PR & Administration: 3% (¥1,298,868)។*

***៦-ការអនុម័តលើ Draft Annual Work Program and Budget for FY2015 and Multi-Year Work Program for FY2014-2016:***

*អង្គប្រជុំបានអនុម័តលើ Draft Annual Work Program and Budget for FY2015 ដែលមានគម្រោងកម្មវិធីការងារផ្តោតការយកចិត្តទុកដាក់ទៅលើការជម្រុញសកម្មភាព Trade, Investment,Tourism & Exchange និង PR សំដៅឆ្ពោះទៅការលើកកំពស់សមាហរណកម្មអាស៊ាននៅចុងឆ្នាំ២០១៥ និងក្រោយសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។*

*ថវិកាសម្រាប់ចំណាយលើកម្មវិធីការងារនៅឆ្នាំ២០១៥ មានចំនួនសរុប **¥562,993,000** ហើយត្រូវបានបែងចែក ដូចខាងក្រោម:*

| | | |
|---|---|---|
| *-Japan's Obligation Contribution:* | *¥ 432,730,000* | *¥562,993,000* |
| *-Japan's Voluntary Contribution:* | *¥ 87,789,000* | |
| *-Special Fund:* | *¥ 42,474,000* | |
| ***-ASEAN's Obligation Contribution:*** | ***¥ 49,795,000*** | |

*ក្នុងនោះ វិភាគទានរបស់សមាជិកអាស៊ាននីមួយៗ ត្រូវបង់ជូន AJC for FY2015 មានចំនួន **¥ 4,979,500**។*

*បើធៀបនឹងថវិកាឆ្នាំ២០១៤ ថវិកាឆ្នាំ២០១៥នេះ បានថយចុះ 4% ស្មើនឹង ¥ 23,471,000។*

***ក្នុងការអនុម័តថវិកាឆ្នាំ២០១៥នេះដែរ ខ្ញុំបាទបានផ្តល់ Comment ក្នុងការអនុវត្តផែនការសកម្មភាពការងារឆ្នាំ២០១៥ របស់ AJC ដូចខាងក្រោម:***

***We congratulates to excellent jobs done by the staff of the AJC. Secretary General Ohnishi has worked together for about six years and first year were difficult as they had to work under pressure due to criticism from some members of the diet. The current success of AJC was due to Secretary General's excellent job and management and congratulated him for his work. I wish remaining staff members of AJC to continue to work hard to decrease the gap between old and new members of the ASEAN as especially, AEC is to be established at the end of 2015.***

**៧-<u>ការសម្រេចលើ Next Meeting of Council Director:</u>**

*កិច្ចប្រជុំ Council Director លើកក្រោយ នឹងត្រូវជូនដំណឹងដោយលេខាធិការដ្ឋាន AJC តាមរយៈ កិច្ចប្រជុំ Executive Board Member របស់សមាជិកអាស៊ាន។*

***សូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា នៅឆ្នាំ២០១៦ កម្ពុជានឹងដល់វេនធ្វើជាប្រធានអង្គប្រជុំសម្រាប់ កិច្ចប្រជុំ Council Director លើកទី៣៥។***

*សូមជូនភ្ជាប់នូវរបាយការណ៍លទ្ធផល និងឯកសារនៃកិច្ចប្រជុំ Council Director លើកទី៣៤។*

*សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ-សម្រេច និងជ្រាបជារបាយការណ៍ តាមការគួរ ។*

*សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ ។*

*ឯកអគ្គរាជទូត*

*ហោ មុនីរ័ត្ន*